ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តបាត់ដំបង
លេខ : ៨៨០/១៩ សហវ

ថ្ងៃ សុក្រ ១០កើត ខែ ចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
បាត់ដំបង,ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ២០១៩

ជម្រាបជូន

-ឯកឧត្តម ឧត្តមសេនីយ៍ឯកមេបញ្ជាការយោធភូមិភាគទី៥
-ឯកឧត្តម ឧត្តមសេនីយ៍ទោ ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្ត
-ឯកឧត្តម ឧត្តមសេនីយ៍ទោ មេបញ្ជាការ នៃបញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករងបាត់ដំបង
-ឯកឧត្តម ឧត្តមសេនីយ៍ត្រី មេបញ្ជាការ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត
-លោកអភិបាល នៃគណៈអភិបាល ក្រុង ស្រុក ក្នុងខេត្ត
-លោក លោកស្រី ប្រធាន ស្ថាប័ន មន្ទីរ អង្គភាពជំនាញ ជុំវិញខេត្ត
-លោក លោកស្រី ប្រធានក្រុមហ៊ុន សហគ្រាស អាជីវកម្មដ្ឋាន គ្រឹះស្ថានសិក្សា វត្តអារាមក្នុងខេត្ត

កម្មវត្ថុ: ស្តីពីការរៀបចំបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ គ.ស២០១៩ ។
យោង: ផែនការណែនាំលេខ ០២/២០១៩ គជបអ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ។

តបតាមកម្មវត្ថុកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម ឧត្តមសេនីយ៍ លោកជំទាវ លោក លោកស្រី ជាប្រធាន ស្ថាប័ន មន្ទីរ-អង្គភាព រដ្ឋបាលក្រុង-ស្រុក ប្រធានក្រុមហ៊ុន សហគ្រាស អាជីវកម្មដ្ឋាន គ្រឹះស្ថានសិក្សា និងវត្តអារាមក្នុងខេត្តជ្រាបថា: ការរៀបចំបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០១៩ រដ្ឋបាលខេត្តសូមដាក់ចេញនូវការកំណត់មួយចំនួនដូចខាងក្រោម ៖

១-គ្រប់ស្ថាប័ន មន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុក គ្រឹះស្ថានសិក្សារដ្ឋ ឯកជន និងវត្តអារាម ជុំវិញខេត្ត ត្រូវរៀបចំតាំងព្រះបរមឆាយាល័ក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ព្រះបរមឆាយាល័ក្ខណ៍ **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដោយមានតុបតែងលម្អកំណាត់បូ បំភ្លឺភ្លើងពណ៌ និងចងបដាពាក្យស្លោក ចងទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ទង់ក្បែប ទង់រំយោល នៅតាមមុខ ស្ថាប័ន មន្ទីរ អង្គភាពរៀងៗខ្លួន ។

២-គ្រប់រដ្ឋបាលក្រុង ស្រុក ត្រូវណែនាំដល់ប្រជាជនដែលមានលំនៅដ្ឋានជាប់នឹងផ្លូវលំក្នុង ក្រុង ស្រុក ឃុំ សង្កាត់ ត្រូវដោតទង់ជាតិនៅមុខលំនៅដ្ឋានអោយបានព្រមៗគ្នា ។

៣-ការចងបដាពាក្យស្លោក ត្រូវចាប់ផ្តើមដាក់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៩ (ពាក្យស្លោក និងលេខបដា ដូចមានក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយ) ។

អាស្រ័យហេតុនេះ សូមឯកឧត្តម ឧត្តមសេនីយ៍ លោកជំទាវ លោក លោកស្រី ជាប្រធាន ស្ថាប័ន មន្ទីរ-អង្គភាព រដ្ឋបាលក្រុង-ស្រុក ប្រធានក្រុមហ៊ុន សហគ្រាស អាជីវកម្មដ្ឋាន គ្រឹះស្ថានសិក្សា វត្តអារាមក្នុងខេត្ត ចាត់ចែងអនុវត្ត ឲ្យទទួលបានលទ្ធផល ល្អប្រសើរ ។

សូម ឯកឧត្តម ឧត្តមសេនីយ៍ លោកជំទាវ លោក លោកស្រី ទទួលនូវការគោរពដ៏ស្មោះអំពីខ្ញុំ ។

អភិបាលខេត្ត

ឃួន រតនៈ

ចម្លងជូន

- *ក្រុមប្រឹក្សាខេត្ត*

  *"**ដើម្បីគោរពជូនជ្រាប**"*

- *ឯកសារ-កាលប្បវត្តិ*